**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ២៤៦ **អយក.**ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជាសម្រាប់ការស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងការបង្កើតសាលាថ្នាក់បណ្ឌិត

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការរៀបចំនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- បានឃើញប្រកាសលេខ ១៩៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យលម្អិតសម្រាប់គ្រឹះស្ថានឧត្តមសិក្សា
- បានឃើញប្រកាសលេខ ២៩១៤ អយក.ប្រក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ ស្តីពីលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យលម្អិតសម្រាប់ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .- គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើតគណកម្មាធិការវិទ្យាសាស្ត្រកម្ពុជាសម្រាប់ការស្រាវជ្រាវ និងការបណ្តុះបណ្តុះបណ្តាលថ្នាក់បណ្ឌិត សរសេរអក្សរកាត់ **គ.ក.ស.ប** ដើម្បីសម្របសម្រួលយន្តការត្រួតពិនិត្យ តាមដានការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

### ប្រការ២ .- គោលដៅ

ប្រកាសនេះមានគោលដៅដូចតទៅៈ

- ពង្រឹងគុណភាពនៃការស្រាវជ្រាវវិទ្យាសាស្ត្រ និងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- រៀបចំរចនាសម្ព័ន្ធ និងតួនាទីរបស់ **គ.ក.ស.ប**
- កំណត់អំពីលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាលាថ្នាក់បណ្ឌិត
- ជំរុញការអនុវត្តគោលនយោបាយ និងក្របខណ្ឌច្បាប់ក្នុងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

**ប្រការ៣ .- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់សាលាថ្នាក់បណ្ឌិតទាំងអស់ដែលបាន និងកំពុងធ្វើការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤ .- និយមន័យ**

សាលាថ្នាក់បណ្ឌិត សំដៅដល់រចនាសម្ព័ន្ធផ្នែកវិទ្យាសាស្ត្រដែលផ្ដោតលើការបណ្ដុះបណ្ដាលកម្រិតបណ្ឌិតតាមសក្ដានុពលនៃជំនាញឯកទេសរបស់គ្រឹះស្ថានសិក្សា។ សាលានេះអាចជាគ្រឹះស្ថានឧត្ដមសិក្សាតែមួយ ឬជាការរួមបញ្ចូលគ្នានូវគ្រឹះស្ថានឧត្ដមសិក្សាពីរ ឬច្រើនដែលមានការបណ្ដុះបណ្ដាលលើជំនាញឯកទេសដូចគ្នា ឬជាកន្លែងប្រមូលផ្ដុំនិងតម្រង់ទិសការបណ្ដុះបណ្ដាលជំនាញឯកទេសផ្សេងៗ ដើម្បីធានាការបណ្ដុះបណ្ដាលស្របតាមស្តង់ដាជាតិ និងអន្តរជាតិ។

គណៈកម្មាធិការកម្ពុជាសម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត ដែលហៅកាត់ថា **គ.ក.ស.ប** សំដៅដល់យន្តការ រចនាសម្ព័ន្ធគាំទ្រ និងជាសេនាធិការរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួង ស្ថាប័នពាក់ព័ន្ធលើកិច្ចការស្រាវជ្រាវវិទ្យាសាស្ត្រនិងការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត ដើម្បីធានាគុណភាពនៃការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត។ **គ.ក.ស.ប** ត្រូវមានស្វ័យភាពផ្នែកវិទ្យាសាស្ត្រសម្រាប់ការបណ្ដុះបណ្ដាល និងការស្រាវជ្រាវវិទ្យាសាស្ត្រ និងត្រូវចូលរួមត្រួតពិនិត្យវាយតម្លៃនិក្ខេបបទ។

## ជំពូកទី២

## ការបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជាសម្រាប់ការស្រាវជ្រាវ និងការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត

**ប្រការ៥ .- ការបង្កើត គ.ក.ស.ប**

ត្រូវបានបង្កើតគណៈកម្មាធិការវិទ្យាសាស្ត្រកម្ពុជាសម្រាប់ការស្រាវជ្រាវ និងការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត **គ.ក.ស.ប** ដែលជាយន្តការ និងជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានសិក្សាពាក់ព័ន្ធ ដើម្បីពង្រឹងគុណភាពនៃការបណ្ដុះបណ្ដាល និងជំរុញការស្រាវជ្រាវថ្នាក់បណ្ឌិតនៅកម្ពុជា។ **គ.ក.ស.ប** ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៦ .- សមាសភាព គ.ក.ស.ប**

**គ.ក.ស.ប** មានសមាសភាពមកពីគ្រឹះស្ថានឧត្ដមសិក្សាសាធារណៈ និងឯកជន អង្គភាពស្រាវជ្រាវវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា និងអន្តរជាតិដែលពាក់ព័ន្ធនិងការស្រាវជ្រាវវិទ្យាសាស្ត្រ និងការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត។ **គ.ក.ស.ប** មានសមាសភាពដូចខាងក្រោម៖

- តំណាងមួយរូបជាអ្នកស្រាវជ្រាវិទ្យាសាស្ត្រដែលមានសញ្ញាបត្របណ្ឌិត មកពីគ្រប់សាលាថ្នាក់បណ្ឌិត។ ដើម្បីចាប់ផ្ដើមដំណើរការការងាររបស់ **គ.ក.ស.ប** បន្ទាប់ពីប្រកាសនេះចូលជាធរមានក្នុងកំឡុងពេលដប់ពីរខែដំបូង គ្រឹះស្ថានឧត្ដមសិក្សាដែលមានបំណងបង្កើតសាលា



៧៤៣

ថ្នាក់បណ្ឌិត ត្រូវបញ្ជូនសមាសភាពមួយរូបមកក្រសួងអប់រំ យុវជន និងកីឡាដើម្បីពិនិត្យ និងសម្រេចដាក់បញ្ចូលជាសមាជិក **គ.ភ.ស.ប**

- សាស្ត្រាចារ្យ ឬអ្នកស្រាវជ្រាវបរទេសមានសញ្ញាបត្របណ្ឌិត និងមានជំនាញត្រូវនឹងសាលាថ្នាក់បណ្ឌិត (ចំនួនសមាជិកនេះអាចមានចំនួនតិចជាង ឬស្មើនឹងចំនួនតំណាងមកពីសាលាថ្នាក់បណ្ឌិត)
- តំណាងមួយរូបមកពីក្រសួងពាក់ព័ន្ធដូចជាក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងការពារជាតិ ក្រសួងបរិស្ថាន ក្រសួងធម្មការនិងសាសនា។ល។
- តំណាងមួយរូបមកពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- តំណាងមួយរូបមកពីក្រុមប្រឹក្សានៃសាលកវិទ្យាធិការកម្ពុជា
- តំណាងមួយរូបមកពីសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
- តំណាងមួយរូបមកពីសភាពាណិជ្ជកម្មកម្ពុជា

សមាជិកភាពនៃ **គ.ភ.ស.ប** មិនត្រូវលើសពីពីរអាណត្តិដែលអាណត្តិនីមួយៗមានរយៈពេលបីឆ្នាំ។

ចំនួន និងសមាសភាពជាក់ស្តែង អាចប្រែប្រួលទៅតាមការវិវត្តរបស់សាលាថ្នាក់បណ្ឌិតដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ប្រការ៧ .- ការដឹកនាំ និងគ្រប់គ្រងនៃ គ.ភ.ស.ប

**គ.ភ.ស.ប** ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានចំនួនពីររូប។

ដើម្បីឱ្យមានប្រសិទ្ធភាព និងសុខដុមនីយកម្មក្នុងការអនុវត្តការងារ **គ.ភ.ស.ប** ត្រូវមានប្រធានកិត្តិយសមួយរូប ជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាក្នុងអាណត្តិនៃរាជរដ្ឋាភិបាល។

- ប្រធាន និងអនុប្រធានទីមួយ ត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតចេញពីសមាជិកវិទ្យាសាស្ត្រ (សាស្ត្រាចារ្យ ឬជំនាញការវិទ្យាសាស្ត្រ) នៃ **គ.ភ.ស.ប**
- អនុប្រធានទីពីរ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតចេញពីតំណាងក្រសួង គ្រឹះស្ថានឧត្តមសិក្សា និងវិទ្យាស្ថានស្រាវជ្រាវដោយសម្លេងភាគច្រើនដាច់ខាត។

ការិយាល័យរបស់ **គ.ភ.ស.ប** ត្រូវស្ថិតនៅក្នុងបរិវេណក្រសួងអប់រំ យុវជន និងកីឡា។

**គ.ភ.ស.ប** ត្រូវមានលេខាធិការដ្ឋានមួយដែលមានទីតាំងស្ថិតនៅក្រសួងអប់រំ យុវជន និងកីឡា។

## ប្រការ៨ .- ភារកិច្ចរបស់ គ.ភ.ស.ប

**គ.ភ.ស.ប** មានភារកិច្ចដូចខាងក្រោមៈ

- ជំរុញដំណើរការសាលាថ្នាក់បណ្ឌិត ក្នុងការធានាការគោរពនីតិវិធី និងបទដ្ឋានគតិយុត្តនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ពង្រឹងគុណភាពនៃការស្រាវជ្រាវ តាមរយៈការបង្កើនស្តង់ដាគុណភាពអប្បរមា សម្រាប់ការរៀបចំ និងការសរសេរនិក្ខេបបទ និងការដឹកនាំការសរសេរនិក្ខេបបទ ការជ្រើសរើសគណៈកម្មការវាយតម្លៃនិក្ខេបបទ



ឲ្យ lem

- បង្កើតលក្ខណៈវិនិច្ឆ័យសាលាថ្នាក់បណ្ឌិត និងធានាគុណភាពផ្នែកវិទ្យាសាស្ត្រនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវវិទ្យាសាស្ត្រ
- លើកកម្ពស់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងការស្រាវជ្រាវវិទ្យាសាស្ត្រនៅកម្ពុជា
- តម្រង់ទិសសាកលវិទ្យាល័យ និងវិទ្យាស្ថាននានាទាំងគ្រឹះស្ថានសាធារណៈ និងឯកជន លើក្របខណ្ឌបណ្តុះបណ្តាល
- ជំរុញសាលាថ្នាក់បណ្ឌិតក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន និងជួយដោះស្រាយបញ្ហានានាដែលជួបប្រទះ
- ជំរុញការបណ្តុះបណ្តាលលើមុខជំនាញ ដែលឆ្លើយតបទៅនឹងតម្រូវការក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ក្នុងប្រទេស តំបន់ និងពិភពលោក
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា សាលាថ្នាក់បណ្ឌិត មន្ទីរពិសោធន៍ស្រាវជ្រាវ និងក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាធិការ ដើម្បីជួយកំណត់ទិសដៅសំខាន់ៗក្នុងកិច្ចការបណ្តុះបណ្តាល និងការស្រាវជ្រាវនៅកម្ពុជា
- ពិនិត្យ និងសម្រេចក្នុងការជ្រើសរើសសាកលវិទ្យាល័យ ឬវិទ្យាស្ថាន សម្រាប់បង្កើតសាលាថ្នាក់បណ្ឌិតតាមជំនាញនីមួយៗ
- កំណត់ក្របខណ្ឌច្បាប់ និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសទីតាំងជំនាញការ និងសាស្ត្រាចារ្យកម្ពុជា និងបរទេសសម្រាប់ចូលជាសមាជិករបស់ **ស.ភ.ស.ប**
- ទទួលភារកិច្ចផ្សេងៗទៀតស្របតាមភាពចាំបាច់នៃការវិវត្តសេដ្ឋកិច្ច សង្គមនៅកម្ពុជា។

**ប្រការ៩ .- ដំណើរការ និងយន្តការនៃ គ.ភ.ស.ប**

**គ.ភ.ស.ប** ត្រូវមានរបបប្រជុំរបស់ខ្លួនជាទៀងទាត់មួយត្រីមាសម្តង។ រាល់ការសម្រេចកិច្ចការផ្សេងៗ ត្រូវមានការឯកភាពដោយសម្លេងភាគច្រើនដាច់ខាត។ លេខាធិការដ្ឋានជាសេនាធិការឱ្យ **គ.ភ.ស.ប** ក្នុងការរៀបចំកិច្ចប្រជុំ សរសេររបាយការណ៍ និងកិច្ចការផ្សេងៗ។

**ប្រការ១០ .- ប្រភពថវិកាបម្រើឱ្យដំណើរការ គ.ភ.ស.ប**

**គ.ភ.ស.ប** ត្រូវមានថវិកាសម្រាប់ដំណើរការការងារដែលមានប្រភពមកពី៖

- ថវិកាជាតិ ជាឧបសម្ព័ន្ធនៃនាយកដ្ឋានហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ថវិកាដៃគូរអភិវឌ្ឍន៍និងប្រភពស្របច្បាប់ផ្សេងៗទៀត
- ថវិកាចំណូលបង់ថ្លៃសិក្សារបស់បេក្ខជនបណ្ឌិត។

## ជំពូកទី៣
## ការបង្កើតសាលាថ្នាក់បណ្ឌិត

**ប្រការ១១ .- ការបង្កើតសាលាថ្នាក់បណ្ឌិត**

ត្រូវបង្កើតសាលាថ្នាក់បណ្ឌិតចំនួនប្រាំពីរ ទៅប្រាំបួនសម្រាប់បណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា លើមុខជំនាញឯកទេសដូចខាងក្រោម៖

- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញវិទ្យាសាស្ត្រនយោបាយ ច្បាប់ សេដ្ឋកិច្ចគ្រប់គ្រង និងសង្គមវិទ្យា
- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញកសិកម្ម រុក្ខវិទ្យា អាហាររូបត្ថម្ភ រុក្ខាប្រមាញ់ និងនេសាទ និងបរិស្ថាន
- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញវិស្វកម្ម វិទ្យាសាស្ត្រវិស្វកម្ម និងស្ថាបត្យកម្ម
- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញភាសា ភាសាវិទ្យា អក្សរសាស្ត្រ និងទស្សនវិជ្ជា
- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញគណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា
- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញបុរាណវិទ្យា វប្បធម៌ ទេវវិទ្យា សិល្បៈ និងសាសនា
- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញវិទ្យាសាស្ត្រសុខាភិបាល
- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញអប់រំ ចិត្តវិទ្យា និងកីឡា
- បង្កើតសាលាថ្នាក់បណ្ឌិតលើជំនាញប្រវត្តិសាស្ត្រ ភូមិវិទ្យា ភូមិសាស្ត្រនយោបាយ និងការពារជាតិ។

គ្រឹះស្ថានឧត្តមសិក្សា មានសិទ្ធិស្នើសុំបើក និងដំណើរការសាលាថ្នាក់បណ្ឌិតលើជំនាញឯកទេសខាងលើ ដោយគោរពទៅតាមលក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យនៃសាលាថ្នាក់បណ្ឌិត។

សាលាថ្នាក់បណ្ឌិតត្រូវបង្កើតដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា តាមសំណើរបស់ **គ.ភ.ស.ប** ។

ចំនួនសាលាថ្នាក់បណ្ឌិតអាចប្រែប្រួលទៅតាមតម្រូវការ និងការវិវត្តស្ថានភាពជាក់ស្តែងនៃការស្រាវជ្រាវ និងបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅព្រះរាជាណាចក្រកម្ពុជា។

## ប្រការ១២ .- លក្ខណៈវិនិច្ឆ័យនៃសាលាថ្នាក់បណ្ឌិត

លក្ខណៈវិនិច្ឆ័យនៃសាលាថ្នាក់បណ្ឌិតលើជំនាញខាងលើ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងដាច់ដោយឡែក ដែលរៀបចំដោយសាលាថ្នាក់បណ្ឌិត ដើម្បីដាក់ជូន **គ.ភ.ស.ប** ពិនិត្យនិង សម្រេច។

## ប្រការ១៣ .- ភារកិច្ច និងការទទួលខុសត្រូវរបស់សាលាថ្នាក់បណ្ឌិត

សាលាថ្នាក់បណ្ឌិតមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ទទួលយកនិស្សិតចូលរៀនថ្នាក់បណ្ឌិត និងត្រូវធានាថានិស្សិតបានបំពេញតាមលក្ខខណ្ឌដូចតទៅ៖
  - មានប្រធានបទសម្រាប់គម្រោងស្នើស្រាវជ្រាវថ្មី មានសាស្ត្រាចារ្យណែនាំដែលជាអ្នកស្រាវជ្រាវមានជំនាញវិជ្ជាជីវៈ លើប្រធានបទនោះ
  - ចេះភាសាបរទេសច្បាស់លាស់ ដែលអាចប្រើប្រាស់ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ
  - មានសារតាសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ស្របទៅនឹងជំនាញឯកទេសដែលជ្រើសរើស



ទ្យ ៤៣

- ធានាថាសំណើគម្រោងស្រាវជ្រាវរបស់និស្សិតថ្នាក់បណ្ឌិតមានលក្ខណៈវិទ្យាសាស្ត្រ ស្រប តាមបច្ចុប្បន្នភាពនៃការវិវត្តវិទ្យាសាស្ត្រ
- គ្រប់គ្រងការងាររបស់និស្សិតថ្នាក់បណ្ឌិត ដូចជា នីតិវិធីក្នុងការចុះឈ្មោះចូលសិក្សា និងការ ចុះឈ្មោះប្រចាំឆ្នាំសិក្សា តាមដានការវិវត្ត និងគុណភាពការងារស្រាវជ្រាវរបស់និស្សិតថ្នាក់ បណ្ឌិត ដោយមានការចូលរួមពីគណៈកម្មការវាយតម្លៃនិក្ខេបបទ រៀបចំគណៈកម្មការវាយ តម្លៃសម្រាប់ការពារនិក្ខេបបទ
- ជំរុញឱ្យមានការផ្លាស់ប្តូរបទពិសោធន៍ផ្នែកវិទ្យាសាស្ត្រ រវាងក្រុមនិស្សិតថ្នាក់បណ្ឌិតដែល មានជំនាញខុសគ្នាជាមួយក្រុមអ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យដឹកនាំផ្សេងទៀត ជាពិសេស តាមរយៈព្រឹត្តិការណ៍នានាដូចជាសន្និសីទ សិក្ខាសាលា បទបង្ហាញ និងទិវាផ្សេងៗ
- លើកទឹកចិត្តនិស្សិតថ្នាក់បណ្ឌិត និងសាស្ត្រាចារ្យដឹកនាំ ចូលរួមនៅក្នុងព្រឹត្តិការណ៍វិទ្យា សាស្ត្រជាតិ តំបន់ និងអន្តរជាតិ
- ផ្តល់ដល់និស្សិតថ្នាក់បណ្ឌិតនូវរាល់ព័ត៌មានចាំបាច់នានាពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវ និង វគ្គសិក្សាផ្សេងៗ

### ប្រការ១៤ ._ ដំណើរការ និងយន្តការសាលាថ្នាក់បណ្ឌិត

សាលាថ្នាក់បណ្ឌិត ត្រូវដឹកនាំដោយនាយក/នាយិកាមួយរូប នាយក/នាយិការងមួយរូប និងមាន សមាជិកពីររូប។

នាយក/នាយិកា នាយក/នាយិការង និងសមាជិកពីររូប ត្រូវជ្រើសរើសចេញពីសាស្ត្រាចារ្យ ស្រាវជ្រាវ ឬអ្នកស្រាវជ្រាវពីក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាដែលជាសមាជិករបស់សាលាថ្នាក់បណ្ឌិត ហើយដែលត្រូវមានគុណវុឌ្ឍិដូចខាងក្រោមៈ

- មានសញ្ញាបត្រថ្នាក់បណ្ឌិត
- ជាសាស្ត្រាចារ្យស្រាវជ្រាវ ឬអ្នកស្រាវជ្រាវដែលមានបទពិសោធន៍ការងារស្រាវជ្រាវយ៉ាង តិចប្រាំឆ្នាំ
- មានបទពិសោធន៍ក្នុងការដឹកនាំនិស្សិតថ្នាក់បណ្ឌិត យ៉ាងតិចប្រាំរូប
- មានស្នាដៃបោះពុម្ពអត្ថបទស្រាវជ្រាវ យ៉ាងតិចប្រាំ ដែលបានចុះផ្សាយក្នុងក្របខណ្ឌជាតិ តំបន់ ឬអន្តរជាតិ។

គ្រប់សាលាថ្នាក់បណ្ឌិត ត្រូវមានលេខាធិការដ្ឋានមួយ ដែលមានទីតាំងស្ថិតនៅក្នុងគ្រឹះស្ថានឧត្តម សិក្សាដែលបើកសាលាថ្នាក់បណ្ឌិតនោះ។

សាលាថ្នាក់បណ្ឌិតនីមួយៗ ត្រូវរៀបចំការប្រជុំជាមួយសមាជិកដទៃទៀតរបស់ខ្លួនឱ្យបានយ៉ាង តិចបំផុតពីរដងក្នុងមួយឆ្នាំ។

សាលាថ្នាក់បណ្ឌិតត្រូវមានក្រុមសាស្ត្រាចារ្យស្រាវជ្រាវដែលមានសញ្ញាបត្របណ្ឌិត និងត្រូវតែជា អ្នកស្រាវជ្រាវសកម្ម ឬជាអ្នកធ្វើការងារក្នុងមន្ទីរពិសោធន៍ស្រាវជ្រាវដែលមានការទទួលស្គាល់ជាលក្ខណៈ ជាតិ តំបន់ ឬអន្តរជាតិ។

និស្សិតថ្នាក់បណ្ឌិត ត្រូវចុះឈ្មោះចូលរៀន រៀន និងធ្វើការស្រាវជ្រាវស្របតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តិដែលមានជាធរមាន។

និស្សិតថ្នាក់បណ្ឌិត អាចចូលទៅសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលនានា ដែលជាសមាជិករបស់សាលាថ្នាក់បណ្ឌិត លើមុខវិជ្ជាបំពេញបន្ថែមផ្សេងៗ តាមរយៈការសម្របសម្រួលផ្ទៃក្នុងរបស់គ្រឹះស្ថានដែលជាសមាជិករបស់សាលាថ្នាក់បណ្ឌិតនោះ។

សាលាថ្នាក់បណ្ឌិត អាចរៀបចំជាព្រឹត្តិការណ៍វិទ្យាសាស្ត្រផ្សេងៗ ឬវេទិកាអ្នកស្រាវជ្រាវវិទ្យាសាស្ត្រ ឬទិវាអ្នកស្រាវជ្រាវ ដើម្បីឱ្យបេក្ខជនបណ្ឌិតចូលរួមធ្វើបទបង្ហាញ ពិភាក្សា លើប្រធានបទណាមួយដែលចាត់ទុកថាមានសារៈប្រយោជន៍សម្រាប់និស្សិតថ្នាក់បណ្ឌិតទាំងអស់។

## ប្រការ១៥ .- លក្ខខណ្ឌវិទ្យាសាស្ត្រ និងរដ្ឋបាលនៃការចូលជាសមាជិកសាលាថ្នាក់បណ្ឌិត

គ្រឹះស្ថានសិក្សា អាចដាក់ពាក្យស្នើសុំចូលជាសមាជិកនៃសាលាថ្នាក់បណ្ឌិត ដូចប្រការខាងលើនេះ លុះត្រាតែបានបំពេញលក្ខខណ្ឌវិទ្យាសាស្ត្រ និងរដ្ឋបាលព្រមទាំងបានទទួលការឯកភាពពី **គ.ភ.ស.ប** ។

លក្ខខណ្ឌវិទ្យាសាស្ត្រ និងរដ្ឋបាលនៃការចូលជាសមាជិកសាលាថ្នាក់បណ្ឌិត ត្រូវកំណត់ដោយលិខិតបទដ្ឋានដោយឡែករៀបចំដោយ **គ.ភ.ស.ប**។

គ្រឹះស្ថានឧត្តមសិក្សា ដែលមានការបណ្តុះបណ្តាលថ្នាក់បណ្ឌិតដែលមិនទាន់បំពេញបាននូវលក្ខខណ្ឌវិទ្យាសាស្ត្រ និងរដ្ឋបាលរបស់សាលាថ្នាក់បណ្ឌិត អាចស្នើសុំចូលជាសមាជិកនៃសាលាថ្នាក់បណ្ឌិត រយៈពេលដប់ពីរខែ ដោយត្រូវបំពេញរាល់កង្វះខាតតាមអនុសាសន៍របស់ **គ.ភ.ស.ប**។

ការចូលជាសមាជិកសាលាថ្នាក់បណ្ឌិតត្រូវដាក់ពាក្យស្នើសុំទៅ **គ.ភ.ស.ប**។

ចំពោះគ្រឹះស្ថានឧត្តមសិក្សា ដែលជាសមាជិកនៃសាលាថ្នាក់បណ្ឌិត តែមិនបានអនុវត្តតាមលក្ខខណ្ឌវិទ្យាសាស្ត្រ និងរដ្ឋបាលរបស់សាលាថ្នាក់បណ្ឌិតនឹងត្រូវបាត់បង់សមាជិកភាពនៃសាលាថ្នាក់បណ្ឌិតតាមការសម្រេចរបស់ **គ.ភ.ស.ប**។

គ្រឹះស្ថានឧត្តមសិក្សាដែលមានមុខជំនាញសិក្សាច្រើន អាចចូលជាសមាជិករបស់សាលាថ្នាក់បណ្ឌិតលើសពីមួយស្របតាមមុខវិជ្ជាជំនាញដែលមាននៅក្នុងគ្រឹះស្ថានឧត្តមសិក្សានោះ។

ការចូលជាសមាជិករបស់សាលាថ្នាក់បណ្ឌិតណាមួយ ឬការបណ្តេញសមាជិកភាពរបស់គ្រឹះស្ថានឧត្តមសិក្សាពីសាលាថ្នាក់បណ្ឌិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាតាមសំណើរបស់ **គ.ភ.ស.ប**។

ចំពោះគ្រឹះស្ថានឧត្តមសិក្សា ដែលបានបំពេញទៅតាមលក្ខខណ្ឌវិទ្យាសាស្ត្រ និងរដ្ឋបាលរបស់សាលាថ្នាក់បណ្ឌិត និងជាសមាជិករបស់សាលាថ្នាក់បណ្ឌិត ត្រូវទទួលបានការទទួលស្គាល់គុណភាពលើការបណ្តុះបណ្តាលថ្នាក់បណ្ឌិតដោយ **គ.ភ.ស.ប**។

## ប្រការ១៦ .- ទំនាក់ទំនងនៃសាលាថ្នាក់បណ្ឌិតជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ

គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅកម្ពុជា អាចចូលរួមជាមួយសាលាថ្នាក់បណ្ឌិត ក្នុងការពិភាក្សាលើប្រធានបទស្រាវជ្រាវវិទ្យាសាស្ត្រ តាមការរៀបចំ

ព្រឹត្តិការណ៍ និងវេទិកាវិទ្យាសាស្ត្រផ្សេងៗ ដើម្បីប្រើប្រាស់លទ្ធផលស្រាវជ្រាវ ជាប្រយោជន៍ដល់សង្គម។

## ជំពូកទី៤

## យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ លើដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

### ប្រការ១៧ .- ការត្រួតពិនិត្យតាមដាន

**គ.ក.ស.ប** ត្រូវត្រួតពិនិត្យតាមដានជាប្រចាំលើដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងការងារស្រាវជ្រាវវិទ្យាសាស្ត្រ ហើយលទ្ធផលដែលទទួលបានពីការវាយតម្លៃ ត្រូវផ្សព្វផ្សាយទៅដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ។

**គ.ក.ស.ប** ត្រូវរៀបចំស្តង់ដាសម្រាប់វាយតម្លៃផ្ទៃក្នុង និងផែនការសកម្មភាពសម្រាប់ត្រួតពិនិត្យតាមដាន លើដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

### ប្រការ១៨ .- តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន គ.ក.ស.ប

លេខាធិការដ្ឋានមានភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលជាមួយ **គ.ក.ស.ប** និងស្ថាប័នពាក់ព័ន្ធ
- ជាសេនាធិការឱ្យ **គ.ក.ស.ប** ក្នុងការរៀបចំនិងគ្រប់គ្រងថវិការដើម្បីដំណើរការការងាររបស់ **គ.ក.ស.ប**
- រៀបចំរបាយការណ៍វាយតម្លៃដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

### ប្រការ១៩ .- គ្រឹះស្ថានសិក្សាបំពេញលក្ខខណ្ឌ

គ្រឹះស្ថានឧត្តមសិក្សាដែលកំពុងបណ្តុះបណ្តាលថ្នាក់បណ្ឌិត ហើយពុំទាន់បានបំពេញគ្រប់លក្ខខណ្ឌបណ្តុះបណ្តាល ត្រូវបំពេញក្នុងរយៈពេលបីឆ្នាំ ដើម្បីកែលម្អឱ្យបានត្រឹមត្រូវស្របតាមលក្ខណៈវិនិច្ឆ័យនៃការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងការចូលជាសមាជិកនៃសាលាថ្នាក់បណ្ឌិត។ ក្រោយរយៈពេលកំណត់ខាងលើ បើមិនបានបំពេញគ្រប់លក្ខខណ្ឌ គ្រឹះស្ថានឧត្តមសិក្សានោះនឹងបាត់បង់ឱកាសស្នើសុំចូលជាសមាជិករបស់សាលាថ្នាក់បណ្ឌិតលើជំនាញនោះ ឬបាត់បង់សិទ្ធិក្នុងការស្នើសុំបើក និងដំណើរការសាលាថ្នាក់បណ្ឌិត។

គ្រឹះស្ថានឧត្តមសិក្សា ដែលកំពុងដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត មានសិទ្ធិមិនចូលជាសមាជិកនៃសាលាថ្នាក់បណ្ឌិត ប៉ុន្តែឱកាស និងផលប្រយោជន៍ផ្សេងៗ នឹងត្រូវផ្តល់អាទិភាពដល់សាកលវិទ្យាល័យដែលជាសមាជិក។



ឲ ៤៣

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ២០ ._ និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២១ ._ អនុភាពអនុវត្ត**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានឧត្តមសិក្សា ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និងសាកលវិទ្យាធិការ នាយកវិទ្យាស្ថាន នៃគ្រឹះស្ថានឧត្តមសិក្សានិងវិទ្យាស្ថានស្រាវជ្រាវទាំងអស់ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៧

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងអាណាព្យាបាលគ្រឹះស្ថានឧត្តមសិក្សា
- រាជបណ្ឌិត្យសភាកម្ពុជា
- អង្គភាពក្រោមឱវាទក្រសួង

« ដើម្បីជូនជ្រាប »
- ដូចប្រការ២១ « ដើម្បីអនុវត្ត »
- ឯកសារ-កាលប្បវត្តិ នា.នីតិកម្ម